# San Diego Unified School District

EUGENE BRUCKER EDUCATION CENTER
4100 Normal Street, San Diego, CA  92103-2682


Terry B. Grier, Ed.D.
អគ្គស្នងការអប់រំ

ខែ មិថុនា ឆ្នាំ ២០០៨

មាតាបិតា/អ្នកអាណាព្យាបាលសិស្សជាទីរាប់អាន:

ការសិក្សាទាឆ្នាំនេះនឹងបញ្ចប់នាពេលឆាប់ៗខាងមុខនេះ ខ្ញុំសូមចំណាយពេលវេលាក្នុងពេលនេះដើម្បីសូមថ្លែងអំណរគុណដល់លោកអ្នកដែលបានជួយគាំទ្រដល់ការសិក្សារបស់សិស្ស ព្រមទាំងអរគុណដល់លោកអ្នកអនុញ្ញាតិអោយខ្ញុំធ្វើការបំរើដល់សិស្សនៅតាមសាលារៀនទាំងអស់របស់យើង។

បញ្ហាថវិការនៅតែមានបន្តនៅតាមក្រសួងអប់រំរបស់យើង។ លោកអ្នកបានរួបរួមជាមួយយើងខ្ញុំដាដៃគូរដើម្បីប្រឆាំងនឹងការកាត់បន្ថយថវិការសាលារៀនដល់ការសិក្សារបស់សិស្ស, សាលារៀន និងសហគមន៍របស់យើង។ លទ្ធផលយើងបានទទួលការរីកចំរើនមួយចំនួន។ យើងសូមថ្លែងអំណរគុណដល់លោកអ្នកដែលបានព្យាយាមជួយប្រឹងប្រែងដល់កិច្ចការទាំងនេះ។

លោកចៅហ្វាងខែត្របានធ្វើសេចក្តីរាយការឡើងវិញនាថ្ងៃទី ១៤ ខែ ឧសភា នេះ។ បន្ទាប់មកបុគ្គលិករបស់យើងបានធ្វើការវិភាគអំពី ការបន្ថយថវិការសំរាប់សាលារៀនរបស់យើង។ ចំនួនថវិការដែលកាត់បន្ថយសំរាប់ក្រសួងអប់រំប្រចាំក្រុងរបស់យើងគឺចុះពី ៨០លានដុល្លារ មក ៥៣លានដុល្លារ។ ខ្ញុំស្នើសុំឲ្យលោកចៅហ្វាយខែត្រធ្វើការគិតគូរដល់ការអប់រំជាធំខាងផ្នែកថវិការដែលការត់បន្ថយលើផ្នែកអប់រំដល់សាលារៀន។ គាត់ធ្វើការសើរើស្នើសុំការកាត់បន្ថយថវិការនេះ ហើយនឹងផ្ញើជូនដល់សាលារៀនប្រចាំក្រុងរបស់យើង។

យើងនៅតែបន្តការប្រឆាំងតវ៉ានឹងការកាត់បន្ថយថវិការនេះសំរាប់សាលារៀនរបស់យើង ខ្ញុំជឿជាក់ថា យើងអាចចាប់ផ្តើមរៀបចំរក្សារដាក់កម្មវិធីមួយចំនួនដែលយើងបានកាត់បន្ថយ។ យើងនឹងធ្វើសេចក្តីស្នើសុំអោយគណៈកម្មការក្រសួងអប់រំប្រចាំក្រុងអំពី ការរក្សារកម្មវិធីនេះឡើងវិញ។ យើងនឹងចាប់ផ្តើមរៀបចំចាត់ចែងជាមួយថ្នាក់រៀនរបស់យើង។

បញ្ហាថវិការកើតឡើងនេះពេលនេះ ក៏មានរឿងរ៉ាវល្អៗកើតមានឡើងចំពោះសិស្ស និងសាលារៀនរបស់យើងផងដែរ។ នេះជាឆ្នាំទី ពីរ ដែលសាលារៀនប្រចាំទីក្រុង San Diego ចំនួន ១៥សាលា បានបង្កើតទស្សនាវដ្តីប្រចាំសប្តាហ៍បានល្អប្រសើរ Amrica's Best ប្រចាំសាលាវិទ្យាល័យ។សាលាបឋមសិក្សាចំនួន ប្រាំមួយ បានត្រូវដាក់ឈ្មោះថា California Distinguished ជាសាលារៀនប្រចាំ កាលីហ្វ័រញ៉ា អប់រំសិក្សាសិស្សបានកំរិតខ្ពស់។ លោកគ្រូ-អ្នកគ្រូចំនួន ដប់ប្រាំបួននាក់ បានទទួលសញ្ញាប័ត្រ National Board Teacher Certication ដែលសម្គាល់ថាជាគ្រូមានកំរិតខ្ពស់ខាងផ្នែកអប់រំសិស្ស។ សាលារៀនប្រចាំទីក្រុង San Diego ជាក្រសួងអប់រំមួយក្នុងចំណោមក្រសួងអប់រំធំចំនួនដប់នៅក្នុង U.S. ដែលបានអប់រំសិស្សបានសម្រេចតាមគោលការសិក្សាឆ្នាំ ២០០៦-០៧ ។ សាលារៀនចំនួនដប់ពីរ បានទទួលសញ្ញាប័ត្រ Title I Academic Achievement Awards ដែលសម្គាល់ថា ជាសាលារៀនដែលមានការលូតលាស់។ ការគាំទ្ររបស់លោកអ្នកអាចធ្វើអោយមានការរីកចំរើនយ៉ាងជាក់លាក់។

ទាឆ្នាំខាងមុខនេះ យើងនឹងស្ថាបនាការណែនាំសិស្សសិក្សាអោយបានជ័យជំនះ។ ចាប់ផ្តើមពីរដូវស្លឹកឈើធ្លាក់នេះសាលាវិទ្យាល័យនៅក្នុងក្រសួងអប់រំប្រចាំក្រុងនឹងមានគ្រូកីឡាមានសញ្ញាប័ត្រម្នាក់ ព្រមទាំងនឹងផ្តល់មុខវិជ្ជាកំរិតខ្ពស់យ៉ាងហោចណាស់ចំនួន ១០មុខ (Advanced Placement (AP) Courses) ដល់សិស្សសិក្សា ។ សាលារៀនថ្មីផ្នែកសិល្បៈបច្ចេកទេសចំនួនបួនសាលានឹងបើកបង្រៀនដូចជា: សាលាបឋមសិក្សា Sherman, Mary Lanyon Fay, Memorial Preparatory for Scholars and Athletes, និងសាលាអនុវិទ្យាល័យ Millennial Tech Middle magnet ។ កម្មវិធីបង្រៀនបន្ថែមនឹងជូនដល់សាលារៀន ហើយយើងនឹងបន្តការឧបត្ថមការសិក្សាដែលមានគុណភាពខ្ពស់ដល់សិស្សទាំងអស់។

អរគុណដល់លោកអ្នកដែលមានការទុកចិត្តដល់កូនលោកអ្នកសិក្សានៅតាមសាលារៀនរបស់យើង។ សូមឲ្យលោកអ្នកមានសេចក្តីរីករាយនារដូវក្តៅនេះ!

ដោយក្តីរាក់ទាក់បំផុត

Terry B. Grier, Ed.D.
អគ្គស្នងការអប់រំ

បន្ថែម: ដើម្បីទទួលពត៌មានថ្មីៗពីក្រសួងអប់រំប្រចាំក្រុង និងសាធារណះ សូមជាវពត៌មានថ្មីៗប្រចាំសប្តាហ៍ដែលបោះពុម្ពជារៀងរាល់ថ្ងៃ សុក្រ។ ចូរបើក Quick Links www.sandi.net ដើម្បីមើល។

Superintendent June, 2008. Cambodian Version.